**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**
**អគ្គនាយកដ្ឋានរដ្ឋបាល**
**នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល**
លេខ......០៧៤.........ន.ប.ប.

ថ្ងៃព្រហ. ១៤កើត ខែផល្គុន ឆ្នាំរកា ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១៨

**សូមគោរពជូន**

- **ឯកឧត្តមអគ្គាធិការ នៃអគ្គាធិការដ្ឋាន**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋាន ប.គ.ព.**
- **ឯកឧត្តមប្រធានវិទ្យាស្ថានជាតិ ប.ទ.ប.គ.ព.**
- **ឯកឧត្តមប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា**
- **លោកប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង**
- **លោក លោកស្រីប្រធានមន្ទីរប.ទ.**

**កម្មវត្ថុ** : ស្តីពីការជូនដំណឹងអំពីការបើកវគ្គបណ្តុះបណ្តាលផ្នែករដ្ឋបាលសាធារណៈ និងវគ្គបណ្តុះបណ្តាលការគ្រប់គ្រងអង្គភាពសាធារណៈ នៅសាលាភូមិន្ទរដ្ឋបាល។

**យោង** : -លិខិតលេខ ៧០៣ មស.សករ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ។
-ចំណារឯកភាពរបស់ឯកឧត្តមរដ្ឋមន្ត្រីស្តីទីចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមអគ្គាធិការ ឯកឧត្តមអគ្គនាយក ឯកឧត្តមប្រធានវិទ្យាស្ថានជាតិ លោកប្រធាននាយកដ្ឋាន លោក លោកស្រីប្រធានមន្ទីរប.ទ.** មេត្តាជ្រាបថា សាលាភូមិន្ទរដ្ឋបាលនឹងរៀបចំបើកវគ្គបណ្តុះបណ្តាលវគ្គខ្លីជំនាញផ្នែករដ្ឋបាលសាធារណៈ និងផ្នែកការគ្រប់គ្រងអង្គភាពសាធារណៈ សម្រាប់រយៈពេល១២០ម៉ោង ដល់មន្ត្រីរាជការនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានតម្រូវការសមត្ថភាពទៅតាមជំនាញ នាពេលខាងមុខនេះ។ នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល សូមធ្វើការផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលខាងលើដល់គ្រប់អង្គភាពក្រោមឱវាទក្រសួងប.ទ. ដើម្បីរកបេក្ខជនដែលមានចំណាប់អារម្មណ៍ និងត្រូវតាមលក្ខណ្ឌ ក្នុងការដាក់ពាក្យស្នើសុំ (ដូចមានឯកសារព័ត៌មានលម្អិត និងឈ្មោះវគ្គនីមួយៗ ភ្ជាប់ជូន)។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោក លោកស្រី ប្រធាន** មេត្តាជួយផ្សព្វផ្សាយបន្តជូនដល់មន្ត្រីក្រោមឱវាទដែលមានចំណាប់អារម្មណ៍វគ្គបណ្តុះបណ្តាលខាងលើ និងសូមអនុញ្ញាតឱ្យមន្ត្រីទាំងនោះដាក់ពាក្យស្នើសុំចូលរៀនមកនាយកដ្ឋានបណ្តុះបណ្តាលបន្ត នៃសាលាភូមិន្ទរដ្ឋបាលដោយផ្ទាល់ឲ្យបានមុនថ្ងៃទី**១៦ ខែមីនា ឆ្នាំ២០១៨**។

សូម **ឯកឧត្តម លោក លោកស្រី ប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រធាននាយកដ្ឋាន**

**ជួន ដារ៉ូ**